**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ទីស្ដីការក្រសួងយុត្តិធម៌

លេខ ៣១១ អក-៩៨

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**<u>សូមជម្រាបមក</u>**

លោកប្រធានតុលាការខេត្ត-ក្រុង

<u>សូមជ្រាប។</u>

***<u>កម្មវត្ថុ:</u>*** ករណីគ្មានមេធាវី ដើម្បីការពារជនក្រីក្រនៅតាមបណ្ដាខេត្ត-ក្រុង ។

ខ្ញុំសូមជម្រាបលោកថា ក្រសួងយុត្តិធម៌ជាញឹកញាប់តែងបានទទួលលិខិតពីតុលាការខេត្ត-ក្រុង ដែលបញ្ជាក់ថា ខ្វះខាតមេធាវីដើម្បីការពារជនក្រីក្រ ដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ។ រីឯពិរុទ្ធជនមួយចំនួនទៀតត្រូវបានឃុំខ្លួនហួសថេរវេលាកំណត់នៃច្បាប់ ក៏ព្រោះតែគ្មានមេធាវីជួយការពាររឿងក្ដីរបស់ពួកគេ ។

អាស្រ័យហេតុនេះក្រសួងយុត្តិធម៌ សូមឱ្យលោកប្រធានតុលាការគ្រប់ខេត្ត-ក្រុង ធ្វើសំណើទៅគណៈមេធាវី ដោយភ្ជាប់ទៅជាមួយនូវសេចក្ដីបញ្ជាក់ពីអាជ្ញាធរមូលដ្ឋាន ឃុំ-សង្កាត់ អំពីស្ថានភាពក្រីក្ររបស់ជនជាប់ចោទមកជាមួយផង ។

ក្រសួងសង្ឃឹមថា លោកនឹងអនុវត្តតាមគោលការណ៍នេះ បានយ៉ាងហ្មត់ចត់ដើម្បីពង្រឹងនូវវិស័យច្បាប់ឱ្យកាន់តែល្អប្រសើរ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៩៨

**រដ្ឋមន្ត្រី**

**ចែម ស្គួន**